**SPRING PARKS PRIMARY SCHOOL**
*Learning and Growing - Safety - Together*

**West Campus - Administration**
24 Erica Street, Springvale 3171 ☎ 9546 6402

**Valley Campus**
27-39 Clarke Road, Springvale South 3172 ☎ 9547 3222
✉ spring.parks.ps@education.vic.gov.au springparksps.vic.edu.au

គោរព ចូលរួម លទ្ធផល សហគមន៍ សង្ឃឹម



ជំរាបមាតាបិតា/អាណាព្យាបាល,

## កិច្ចសម្ភាសរវាងមាតាបិតានិងគ្រូ:

ម៉ោងណាត់ជួបសម្ភាសរបស់លោកអ្នកនឹងផ្ញើទៅផ្ទះជូននៅថ្ងៃពុធទី១៤ ខែ មិថុនា(៦),សូមមើលក្នុងកាបូបរបស់កុមារ។បើមាតាបិតាមិនអាចមកក្នុងថ្ងៃនេះបានទេ,សូមទូរស័ព្ទមកការិយាល័យដើម្បីឲ្យបុគ្គលិកការិយាល័យព្យាយមរកថ្ងៃដ៏សមរម្យជំនួស។ គ្រួសារដែលមានកូនស្ថិតក្នុងកម្មវិធីទទួលការគាំទ្រពិសេសនឹងមានពេលបន្ថែម១៥នាទីដើម្បីពិគ្រោះជាមួយគ្រូរបស់កុមារ។របាយការណ៍របស់កុមារនឹងអាចមើលនៅ Sentral Parent Portal នាថ្ងៃច័ន្ទទី១៩/៦,ដូច្នេះសូមលៃយ៉ាងណាអាចចូលក្នុងក្លោងទ្វារពត៌មាននេះឲ្យបានមុននឹងរបាយការណ៍ចេញផ្សាយ។យើងខ្ញុំរង់ចាំជួបគ្រួសារឲ្យបានរឹតតែច្រើនរឹតតែល្អនៅល្ងាចថ្ងៃសម្ភាសន៏នេះ:

ពត៌មានសំខាន់:កិច្ចសម្ភាសន៏របស់ **Mrs Otenstein** នៅសាខាវ៉ាល្លីក្នុងត្រីមាសនេះនឹងប្រព្រឹត្តទ្បើងនៅថ្ងៃអង្គារ ទី២០ ខែ ៦។

### កំណត់ប្រចាំថ្ងៃ 29/5/2023

២៩/៥: ថ្ងៃគំរោងកម្មវិធីសិក្សា-សិស្សសំរាកថ្ងៃនេះ
៣០/៥: ផ្តែដ៏ស្ថិទ្ធស្តាល-សាខាវ៉ាល្លី
០២/៥: ប្រកួតរត់ចម្ងាយនៃកុមារជម្រើស
គោរពទង់ជាតិ:ចាត់ចែងដោយថ្នាក់ 1/2A & 5/6L
០៦/៦: ថ្នាក់ទី 1/2 ទៅ Healesville Sanctuary
០៩/៦: ថ្ងៃអេស្ប៉ាញ៉ុលនៅសាខាខាងលិច
គោរពទង់ជាតិ:ចាត់ចែងដោយថ្នាក់ 5/6B & 3/4L
១២/៦:បុណ្យកំណើតព្រះមហាក្សត្រ:សំរាក១ថ្ងៃ
១៦/៦:គោរពទង់ជាតិ:ចាត់ចែងដោយថ្នាក់ទី 5/6A & 1/2L

## ការចុះឈ្មោះរៀននៃថ្នាក់មូលដ្ឋានសំរាប់ឆ្នាំក្រោយ:

បើកូនលោកអ្នកមានអាយុ៥ឆ្នាំគិតដល់មុនថ្ងៃទី៣០/៤/២០២៤,កុមារមានសិទ្ធិអាចចុះឈ្មោះរៀននៅសាលា។សូមទាក់ទងនឹងការិយាល័យសាលាដើម្បីយកសំណុំបណ្ណចុះឈ្មោះ។បើយើងខ្ញុំដឹងចំនួនសិស្សឆ្នាំ២០២៤មុន,យើងខ្ញុំនឹងមានការងាយស្រួលដើម្បីចាប់ផ្តើមគំរោងការណ៏រៀបចំបុគ្គលិក។

## ពិធីគោរពទង់ជាតិនៃសាលាទាំងមូល:

ទោះជាថ្ងៃនេះនៅឆ្ងាយនៅឡើយ,តែយើងខ្ញុំនឹងចាត់ចែងពិធីនេះនៅសាខាវ៉ាល្លីនាថ្ងៃសុក្រទី២៣/៦វេលាម៉ោង៩:៣០ព្រឹក។ពិធីនេះបានប្រព្រឹត្តឡើងព្រលឹមជាងធម្មតា(ម៉ោង៩:៣០)ព្រោះកុមារថ្នាក់ទី៥/៦ត្រូវទៅប្រកួតកីឡាក្នុងថ្ងៃនេះ, ហើយត្រីមាសទី២ក៏បានបញ្ចប់វេលាម៉ោង ២:៣០ ក្នុងថ្ងៃនេះដែរ។

## ថ្ងៃអេស្ប៉ាញ៉ុល:

Mrs Parisi មានការរវល់មមាញឹកដើម្បីចាត់ចែងទិវាដ៏ល្អវិសេសមួយសំរាប់សហគមន៏សាលាយើងនៅថ្ងៃសុក្រ ទី៩ ខែ មិថុនា។ អ្នកគ្រូបានរៀបចំ paella សំរាប់បាយថ្ងៃត្រង់,ហើយបុគ្គលិកនិងសិស្សសាលាបានបញ្ជាទិញទុកជាមុនពេលបាយថ្ងៃត្រង់ដ៏ឈ្ងុយឆ្ងាញ់នេះ សឹងទាំងអស់គ្នាហើយ។កុមារសាលាយើងបានហាត់រៀនសម្តែងសិល្បៈអេស្ប៉ាញ៉ុល,ហើយយើងទាំងអស់គ្នារង់ចាំមើលការសម្តែងនៃថ្នាក់និមួយៗក្នុងថ្ងៃនេះ។ប្រធានបទនៃថ្ងៃនេះគឺភ្ជង់ទៅលើអេស្ប៉ាញ៉ុលដែលនឹងប្រព្រឹត្តឡើងនៅសាខាខាងលិច។

សូមឲ្យពីរសប្តាហ៏ទៅមុខនេះប្រកបដោយក្តីសុខនិងរីករាយ។

Julie Fisher :
នាយក សាលា

សាលាយើងមានក្តីសោមនស្សជាគូរភាគីនឹង : **Ardoch, IKEA, Woodleigh School, Officeworks & Resilience Project**

## ពិធីប្រណាំងប្រជែងគណិតអូឡាំពិក

នាថ្ងៃទី៨/៥ Ms Wong & Mrs Farmer បានចាត់ចែងពិធីប្រណាំងប្រជែងគណិតអូឡាំពិកដែលមានកុមាចំនួន៣០ចូលរួមចាប់ពីថ្នាក់ទី៥ដល់ថ្នាក់ទី៦នៅសាខាទាំងពីរ។នេះជាការប្រណាំងប្រជែងលើកទី១ក្នុងចំណោម៨លើកដែលត្រូវប្រកួតក្នុងឆ្នាំនេះ។គោលបំណងនៃការប្រណាំងប្រជែងនេះគឺដើម្បីបណ្តុះបណ្តាលទេពកោសល្យដ៏សំខាន់ៗក្នុងការដោះស្រាយចំណោទក្នុងបរិយាកាសដ៏រីករាយហើយពុំមានភាពគំរាមគំហែង។ក្រោយពីបានបំពេញការប្រណាំងប្រជែងចំនួនទាំង៨លើកក្នុងឆ្នាំនេះមក,កុមារនឹងបានទទួលសញ្ញាបត្រសមិទ្ធផល (Certificate of Achievement)។ កុមារណាដែលទទួលជ័យជំនះ(ពិន្ទុច្រើនជាងគេទាំង៨លើក)នឹងបានទទួលពានរង្វាន់ហើយនឹងសញ្ញាបត្រសមិទ្ធផលដែលនឹងផ្តល់ឲ្យនៅពេលគោរពទង់ជាតិពិសេស។រហូតដល់ពេលនេះ,ក្រោយពីការប្រណាំងប្រជែងលើកទី១មក,កុមារដែលមាននាមនៅខាងក្រោមនេះកំពុងនាំមុខគេ។នៅសល់ការប្រជែងចំនួន៣លើកទៀត,ឱកាសទទួលជ័យជំនះអាចធ្លាក់ទៅដល់អ្នករាល់គ្នា។

លេខ១:Jay

លេខ២:(ចំណាត់ថ្នាក់ដូចគ្នា):Alycia, Manreet, Tiffany & Anton

ល្អណាស់!,យើងខ្ញុំចាំមើលថាតើកុមារក្នុងការប្រជែងលើកទី២ដែលនឹងប្រព្រឹត្តទៀងនៅថ្ងៃទី១៥/៦នឹងមានលទ្ធផលយ៉ាងដូចម្តេច?។

## កីឡារត់ចម្ងាយ

ថ្នាក់ទី៤,៥និង៦បានសាករត់ចម្ងាយនៅថ្ងៃសុក្រមុននៅសាខាខាងលិច។កុមារអាយុ១០ឆ្នាំបានរត់២ជុំសាលា(១.៦គីឡូម៉ែត្រ), ហើយកុមារអាយុ១១,១២និង១៣ឆ្នាំរត់៣ជុំ(២.៤គីឡូម៉ែត្រ)។កុមារនិមួយៗនៅ៣ជួរខាងលើរត់បានល្អណាស់ក្នុងលក្ខណ្ឌអាយុ/ភេទ។

ប្រុសអាយុ១២/១៣ឆ្នាំ:Jason N (លេខ១), Jason L (លេខ២), Eren (លេខ៣)

ស្រីអាយុ១២/១៣ឆ្នាំ:Yaya (លេខ១), Anika (លេខ២),Yi Lia (លេខ៣)

ប្រុសអាយុ១១ ឆ្នាំ:Anton (លេខ១), Darrean (លេខ២), Richard (លេខ៣)

ស្រីអាយុ១១ ឆ្នាំ:Emily (លេខ១), Alycia (លេខ២), Cecilia (លេខ៣)

ប្រុសអាយុ១០ ឆ្នាំ: Everrund (លេខ១), Hien (លេខ២), Benjamin (លេខ៣)

ស្រីអាយុ១១ ឆ្នាំ:Ellie (លេខ១), Jennifer (លេខ២), Ameli (លេខ៣)

កុមារនៅជួរលើទាំង៥នឹងទៅប្រកួតនៅថ្នាក់រត់ចម្ងាយប្រចាំសង្កាត់ដែលនឹងប្រព្រឹត្តទៀងនៅថ្ងៃទី២៥/៥នៅ Tatterson Park , Keysborough. Mrs. Farmer, Ms. Wong & Ms. Julie នឹងអមដំណើរកុមារទៅទីប្រកួត។

## ដំណឹងពីការធ្វើដំណើរទៅមកនៃថ្ងៃអេស្ប៉ាញ៉ុល ថ្ងៃសុក្រ ទី៩ មិថុនា ២០២៣

កុមារទាំងឡាយនៃសាខាវ៉ាល្លីនឹងដើរទៅសាខាខាងលិចសំរាប់ថ្ងៃអេស្ប៉ាញ៉ុល។

កុមារនឹងចាកចេញពីសាខាវ៉ាល្លីនៅម៉ោង ៩:០០ព្រឹក ហើយត្រឡប់មកវិញនៅម៉ោង ៣:០០ល្ងាច។

ស្វាគមន៏មាតាបិតា/អាណាព្យាបាលមករួមលេង នឹងសកម្មភាពនានាក្នុង ថ្ងៃអេស្ប៉ាញ៉ុលនេះ

## ថ្នាក់មូលដ្ឋានទៅសារមន្ទីរម៉ែលប៊ុន











## បង្វឹកកីឡាបាល់ទាត់








# ប្រកួតប្រជែងរត់ចម្ងាយប្រចាំសង្កាត់:

នាថ្ងៃព្រហស្បតិ៍ទី២៥/៥/២០២៣,សិស្សថ្នាក់ទី៤,៥,៦ ចំនួន៣០បាន ទៅប្រកួតកីឡារត់ចមងាយប្រចាំសង្កាត់នៅTatterson Park.

កុមារទាំងអស់គ្នាមានទឹកចិត្តដ៏វិជ្ជមានហើយខំព្យាយាមអស់ សមត្ថភាព។មានកុមារ៣រូបខិតខំចូលបានរង្វង់ប្រកួតប្រចាំភូមិភាគ នៃការរត់ចម្ងាយ(តាមចំណាត់ថ្នាក់ពី១ដល់៨គិតតាមក្រុមអាយុ)។ ព្រឹត្តិការណ៏បន្ទាប់នឹងប្រព្រឹត្តទ្បើងនៅថ្ងៃសុក្រ ទី២/៦នៅ Tatterson Park.

សូមអបអរសាទរដល់កុមារដែលមាននាមដូចខាងក្រោមនេះ:
អត្តពលិកប្រុស–អាយុ១០ឆ្នាំ–លេខ ១– Ben Sam (សាខាវ៉ាល្លី)

អត្តពលិកប្រុស–អាយុ១១ឆ្នាំ–លេខ ៥– Anton Mac (សាខាវ៉ាល្លី)

អត្តពលិកនារី–អាយុ១១ឆ្នាំ–លេខ ៨–Japneet Kaur (សាខាខាងលិច)















## STARS OF THE WEEK

### WEST CAMPUS

| Grade | Week 4 | Week 5 |
|---|---|---|
| FA | Nimrat– Ganishka | Thomas– Sebastian |
| 1/2 A | Raisah | Derrick |
| 1/2 B | Jayden | Nehchal |
| 3/4 A | Cassidy | Hamiz |
| 3/4 B | Cherry | Ravneet |
| 5/6 A | Duong | Eric |
| 5/6 B | Japneet | Ben |
| Art | Ailin | |
| PE | Humairah | Siv |
| Spanish | | Aja |

### VALLEY CAMPUS

| Grade | Week 4 | Week 5 |
|---|---|---|
| FK | Jayden | Mateo |
| 1/2 L | Xavier | Ryzo |
| 1/2 M | Alina | Joe 3/4 |
| 3/4 L | Adrian | |
| 3/4 M | Dario | Len |
| 5/6 L | Lucas | Jay |
| 5/6 M | Mia | |
| Art | Jamie | Yilian |
| PE | Destiny | Valentina |
| Spanish | Monika | Quin |